# ចំណុចសំខាន់ៗ(tips) ដើម្បីចៀសវាង ការក្លែងបន្លំ មេឌិឃែរ និង មេឌិខេត

**រាល់ឆ្នាំ អ្នកបង់ពន្ធដារ បាត់បង់ប្រាក់រាប់ពាន់លាន ដុល្លារ (billions) ដោយការក្លែងបន្លំ ក្នុងការថែទាំសុខភាព។** "ការក្លែងបន្លំការថែទាំសុខភាព" អាចមានន័យថា ជនម្នាក់ទាមទារឱ្យអ្នក ឬ ក្រុមហ៊ុន របស់អ្នក បង់ សេវាកម្ម ដែល គេមិនដែលបានផ្តល់ជូនអ្នក។ វាអាចមានន័យផងដែរថា ជនម្នាក់ទាមទារឱ្យអ្នកបង់នូវសេវាកម្មដែលខុសគ្នា ពី អ្វី ដែលគេផ្តល់ជូនអ្នក។ **ជាញឹកញាប់ ការបង់ថ្លៃក្លែងបន្លំ ការពារប្រជាជន មិនឱ្យទទួលសេវាកម្មថែទាំសុខភាព សំខាន់ៗ ដែលពួកគេត្រូវការ។** ឧទាហរណ៍ ក្រុមហ៊ុនឧបករណ៍មួយ ប្រគល់ឱ្យលោក ចូនស៍(Mr. Jones) នូវ ម៉ូតូកង់តូច(scooter) មួយ ប៉ុន្តែ ទាមទារឱ្យ មេឌិឃែរ បង់ថ្លៃរទេះរុញ(wheelchair) ទៅវិញ។ ក្រោយមក នៅ ពេលដែលលោក ចូនស៍ ត្រូវការរទេះរុញ នោះ មេឌិឃែរ មិនព្រមបង់ឱ្យទេ ពីព្រោះគេបានបង់ឱ្យវារួចទៅហើយ។ **កម្មវិធី Illinois SMP នៅទីនេះ គឺដើម្បី ជួយអ្នករៀន អំពី របៀប ការពារ ខ្លួនអ្នក ពីការក្លែងបន្លំនេះ។**

**តទៅនេះជាចំណុចសំខាន់ៗ (tips) ខ្លះ ដើម្បីចៀសវាង ការក្លែងបន្លំ មេឌិឃែរ និង មេឌិខេត:**

- **ចូរកុំ** ឱ្យលេខ មេឌិឃែរ មេឌិខេត ឬលេខ សន្តិសុខសង្គម(Social Security) ទៅជនណាម្នាក់ ដែលអ្នក មិនស្គាល់ឱ្យសោះ។ **មិនត្រូវ** ឱ្យលេខទាំងនេះ ទៅជនណាម្នាក់ ដែលហៅតាមទូរស័ព្ទ ឬ មកកាន់ទ្វារ ជាដាច់ខាត។ អ្នកផ្តល់ការថែទាំសុខភាពដែលអាចជឿទុកចិត្ត នឹងមិនលក់សេវាកម្មរបស់គេ ដោយការ ហៅតាម ទូរស័ព្ទ ឬ ទៅកាន់ទ្វារនោះឡើយ។ **ជាញឹកញាប់ ការផ្សាយលក់តាមទូរស័ព្ទ និង ពីទ្វារមួយទៅ ទ្វារមួយ គឺជាសញ្ញា នៃការក្លែងបន្លំ។** បើអ្នកហៅទូរស័ព្ទ ឬ អ្នកសួរសុខទុក្ខ ព្យាយាមគំរាមកំហែង ឬ បង្ខំឱ្យ អ្នកធ្វើអ្វីមួយ ចូរដាក់ទូរស័ព្ទចុះ ឬ ទាញទ្វារបិទឱ្យជិត។

- **ចូរកុំ** ឱ្យលេខ មេឌិឃែរ មេឌិខេត ឬលេខ សន្តិសុខសង្គម របស់អ្នក ដើម្បី ប្តូរយក សេវាកម្ម "ឥតគិតថ្លៃ" ឱ្យសោះ។ **បើសេវាកម្មនេះ "ឥតគិតថ្លៃ" មែន នោះ គេមិនគប្បីត្រូវការពត៌មានរបស់អ្នកទេ!**

- **ចូរកុំ** ចុះហត្ថលេខា លើ លិខិតស្នាម(forms) ដោយពុំបានអានឱ្យសោះ និង មិនត្រូវចុះហត្ថលេខា លើ លិខិតស្នាម ដែលមានចន្លោះទទេ (blank forms) នោះឡើយ។

- **ចូរកុំ** ទទួលយក សេវាកម្មថែទាំសុខភាព ឬ ឧបករណ៍ ដែលអ្នកមិនត្រូវការនោះឡើយ។ បើជនណាម្នាក់ ផ្តល់ឱ្យអ្នកនូវសេវាកម្ម ឬ ឧបករណ៍ ដែលអ្នកមិនត្រូវការ ហើយ សួររក លេខ មេឌិឃែរ ឬ មេឌិខេត ពួកគេ

## ចំណុចសំខាន់ៗ(tips) ដើម្បីចៀសវាង ការក្លែងបន្លំ មេឌិឃែរ និង មេឌិខេត

ប្រហែលជា ទាមទារឱ្យមេឌិឃែរ ឬ មេឌិខេត ចេញថ្លៃសេវាកម្មទាំងនោះ ដោយក្លែងបន្លំទេ ។ **ត្រូវតែ ពិគ្រោះ ជាមួយ វេជ្ជបណ្ឌិត (គ្រូពេទ្យ) របស់អ្នក បើអ្នកត្រូវការ សេវាកម្មថែទាំសុខភាព។ គ្រូពេទ្យរបស់អ្នក គប្បី បញ្ជាទិញ សេវាកម្ម ឬ សម្ភារៈណា ដែលអ្នកត្រូវការ ។**

- ចូរអាន កំណត់ហេតុ សង្ខេប មេឌិឃែរ **(MSN)** របស់អ្នក ឬ ការពន្យល់នៃ សេចក្តីរាយការណ៍ ស្តីពី អត្ថប្រយោជន៍ ពីគំរោងការណ៍ ធានារ៉ាប់រង របស់អ្នក ។ ត្រូវប្រយ័ត្ន អំពី៖
  - ការទារថ្លៃ សម្រាប់ សេវាកម្ម ឬ សម្ភារៈ ដែលអ្នកមិនបានទទួល
  - សេវាកម្ម ឬ សម្ភារៈ ដែលមិនត្រូវបានបញ្ជាទិញ ដោយគ្រូពេទ្យ របស់អ្នក
  - កំហុស ផ្សេងៗទៀត

(កំណត់សំគាល់៖ ក្នុងរដ្ឋអ៊ីលីណយ ប្រជាជន ដែលមាន មេឌិខេត មិនទទួល សេចក្តីរាយការណ៍ទេ ។ រឿងនេះធ្វើឱ្យ មានការពិបាក ក្នុងការមើលឃើញ ថាតើ ជនណាម្នាក់ កំពុងតែទាមទារឱ្យ មេឌិខេត បង់ថ្លៃ ដោយក្លែងបន្លំ នោះ ។ **ដំណឹងល្អ គឺថា ចំណុចសំខាន់ៗមួយ ក្នុងបណ្តាចំណុចសំខាន់ៗនានា ខាងលើ គឺជាប់ពាក់ព័ន្ធ ទៅនឹង ប្រជាជន ដែលមាន មេឌិខេត ។)**

កម្មវិធី Illinois SMP (ការត្រួតពិនិត្យ មេឌិឃែរ មនុស្សចាស់ជរា _ Senior Medicare Patrol) អប់រំដល់ អ្នកប្រើប្រាស់/ អ្នកបរិភោគ អំពី ការក្លែងបន្លំ ការថែទាំសុខភាព កាកសំណល់ និង ការរំលោភ ។ បើអ្នកមានសំណួរ អំពី ការទាមទារ ពាក់ព័ន្ធនឹង កំណត់ហេតុសង្ខេបមេឌិឃែរ របស់អ្នក ឬ ការពន្យល់ នៃ អត្ថប្រយោជន៍នានា ចូរទូរស័ព្ទទៅ កម្មវិធី Illinois SMP លេខ **(800)699-9043**។ ពត៌មាន ស្តីពី កម្មវិធី Illinois SMP អាចរកបានផងដែរ នៅលើ វ៉ែបសៃរបស់យើងគឺ៖ **www.illinoissmp.org**

ថវិកា សម្រាប់ការបោះពុម្ភនេះ បានត្រូវឧបត្ថម្ភឡើង តាមរយៈប្រាក់ពី អភិបាលកិច្ចសហរដ្ឋអាមេរិក ស្តីពី មនុស្សចាស់ជរា ។